# ការយល់ឃើញរបស់នាងខ្ញុំ

## ដោយ តែ សម្ផស្ស

ក្រោយពីបានអាននូវឯកសារខ្លីៗ ដែលទាក់ទងទៅនឹងការផ្សាយរបស់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីអំពីសម័យប៉ុលពត រួចមក ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅនឹងរឿងរ៉ាវ ដែលបានកើតឡើងនាសម័យនោះ។ ម៉្យាងវិញទៀត ខ្ញុំក៏បានយល់ច្បាស់ពីជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋខ្មែរ នាសម័យដ៏ឃោរឃៅនោះ។ ខ្ញុំពិតជាមានការអាណិតអាសូរយ៉ាងខ្លាំងចំពោះប្រជាជនខ្មែរ ដែលត្រូវរស់នៅស្ថិតក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម ដែលជាមនុស្សឃោរឃៅ គ្មានមេត្តាធម៌ កាប់សំលាប់ ពូជសាសន៍របស់ខ្លួន ដោយគ្មានត្រាប្រណី។ ពួកគាត់ត្រូវបានបង្ខំអោយធ្វើការហួសកំលាំង ហើយទទួលបានរបបអាហារត្រឹមតែបបររាវ ដែលជាហេតុនាំអោយពួកគាត់មានជំងឺដោយសារការបរិភោគមិនគ្រប់គ្រាន់ និងកង្វះអនាម័យ។ អ្វីដែលធ្វើអោយខ្ញុំនឹកស្មានមិនដល់នោះគឺការបរិភោគសាច់មនុស្ស ដើម្បីចំអែតក្រពះ។ នេះគឺជាអំពើសាហាវព្រៃផ្សៃមួយ ដែលភាគច្រើនត្រូវបានគេរកឃើញមានតែក្នុងភាពយន្តប៉ុននោះ។ មូលហេតុទាំងនេះ សបញ្ជាក់អោយឃើញថា ស្ថានភាពរស់នៅរបស់ប្រជាជនខ្មែរនាពេលនោះ ពិតជាមានភាពលំបាកវេទនាយ៉ាងខ្លាំង ដែលជាហេតុធ្វើអោយមនុស្សបង្ខំចិត្តប្រព្រឹត្តអំពើព្រៃផ្សៃដែលពួកគាត់មិនគួរធ្វើ។ ខ្ញុំពិតជាសោកស្តាយយ៉ាងខ្លាំងចំពោះការបាត់បង់នូវចំនួនប្រជាជនខ្មែររាប់លាននាក់ ដែលពួកគាត់ទាំងអស់នោះសុទ្ធតែជាប្រជាជនស្លូតត្រង់ ហើយគ្មានទោសអ្វីទាំងអស់ ។ នេះគឺជារឿងរ៉ាវពិតដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានគេចាត់ទុកជាសោកនាដកម្មដ៏សោកសង្រេងមួយក្នុងប្រវត្តិសាស្ត្រ។ ដូចនេះ យើងជាប្រជាជនកម្ពុជា សូមធ្វើការថ្កោលទោសចំពោះមេដឹកនាំដែលបានសំលាប់ និងបង្អត់អាហារ និងធ្វើទារុណកម្មយ៉ាងឃោរឃៅលើប្រជាជនខ្មែរ ហើយពួកយើងសូមអោយតុលាការសាលាក្តីខ្មែរក្រហមកាត់ទោសមេដឹកនាំទាំងអស់នោះ ដើម្បីផ្តល់យុត្តិធម៌ដល់ប្រជាពលរដ្ឋខ្មែរដែលត្រូវបានសំលាប់នាសម័យនោះ ។

**My Personal Reflection**[1]

By Te Samphors

Phnom Penh

After reading through short documents which related to the broadcast of DC-Cam's Community Radio, I was really interested in the stories from this regime. Besides this, I understood more about the living conditions of the Khmer people in the barbarous period. I felt sympathetic to the people who had to live under the control of the Khmer Rouge leaders. They were very cruel and inhuman. They slaughtered their own race without compassion. People were forced to over work and got only thin rice soup to eat which caused illnessdx due to insufficient food and sanitation. What was really hard to believe was the eating of human flesh. It was a very savage action which we mostly see in movies. All these reasons show that people were having such a hard living that they had to do brutal actions that they didn't want to do. I was very sad that many Khmer people were killed. They were honest and didn't make mistakes. It was a real story which happened in Cambodia. It was one of the most sorrow tragedies in history. As a result, as Cambodians, we want to charge leaders who killed, starved, and tortured people cruelty. Also, we want the Extraordinary Chambers in the Courts of Cambodia to give justice to people who were killed.

[1] Translated by Cheang Channimol; edited by Tan Sock Keng